រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់ចែងធ្វើការផ្ទៀងផ្ទាត់ដោយធ្វើអធិការកិច្ចហិរញ្ញវត្ថុឬការត្រួតពិនិត្យហិរញ្ញវត្ថុតាមការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិច្បាប់ដែលមានការពាក់ព័ន្ធជាធរមាន។

មាត្រា ៧-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៨-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ស ខេង **គាត ឈន់**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចចែងក្នុងមាត្រា៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩៤ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ៣៩៧.៦០០.០០០ រៀល (បីរយកៅសិបប្រាំពីរលាន ប្រាំមួយរយពាន់រៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ជូនក្រសួងធនធានទឹក និង ឧតុនិយម សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនអាជ្ញាធរទន្លេសាប សម្រាប់បន្តសកម្មភាពការងារក្នុងឆមាសទីពីរឆ្នាំ ២០១០។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ៨/០៧ ឆ្នាំ ២០១០



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៦. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ
ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១: - ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃបឹងពែរ ខេត្តកំពង់ធំ លើផ្ទៃដីទំហំ **៨.៣២០ហិកតា (ប្រាំបីពាន់ បីរយម្ភៃហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រឃុំរម្មណីយ៍ និងឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ សម្រាប់ផ្តល់ជូនក្រុមហ៊ុន C.A.D.I CO., LTD ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ និងប្រភេទឈើផ្សេងៗទៀតដែលមានផែនទី និងនិយាមកាជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៨០ សជណ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

មាត្រា២:-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

ស ម្រេ ច

មាត្រា១: – ធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ ត្រង់មាត្រា ១ ចំណុច "ច" ត្រូវបានកែសម្រួលឃ្លាចុងក្រោយ "**ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៦** " មកជាឃ្លាថា: "**ដូចមានក្នុងផែនទី និងនិយាមកា ជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៨១ សជណ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ**" វិញ ដែលមានខ្លឹមសារនៃមាត្រា១ ចំណុច "ច" ដូចខាងក្រោម:

"ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីទំហំ **៩.៩៤៣ហិកតា** (ប្រាំបួនពាន់ ប្រាំបួនរយកៅសិបបីហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ សម្រាប់ផ្ដល់ជូនក្រុមហ៊ុន **អាន ម៉ាឌី** (AN MADY GROUP Co.,LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ និងប្រភេទឈើផ្សេងៗទៀត **ដូចមានក្នុងផែនទី និងនិយាមកា ជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៨១ សជណ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ**"។

មាត្រា២: -

ខ្លឹមសារនៃមាត្រាផ្សេងទៀតរបស់អនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៥ នៅមានសុពលភាពដដែល ។

មាត្រា៣ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៩៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លិខិតលេខ ២៨៣២ អយក.ឧស ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១០

សម្រេច

មាត្រា ១ : ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ** (Cambodian International University) សរសេរកាត់ជាភាសាខ្មែរ " ស.ក.អ " និងសរសេរកាត់ជាភាសាអង់គ្លេស " CamIU "។

មាត្រា ២ : សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ មានទីតាំងឋិតនៅអគារលេខ ៥-១៥ ផ្លូវ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងឋិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣ : សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមហាវិទ្យាល័យប្រាំ និងមានវិទ្យាស្ថានមួយ :

-មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

-មហាវិទ្យាល័យគណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា

-មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ

-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

-មហាវិទ្យាល័យគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច

-វិទ្យាស្ថានអប់រំភាសាអង់គ្លេស

សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល។ ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤ : សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : សាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ មានភារកិច្ច :

-ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀន និងទទួលនិស្សិតឱ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា

-អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ

-រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ និងវិធានផ្ទៃក្នុង សម្រាប់ការគ្រប់គ្រងការសិក្សាឱ្យបានច្បាស់លាស់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា

-ធ្វើរបាយការណ៍ប្រចាំឆ្នាំ មកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

មាត្រា ៦ : និស្សិតសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលារាជធានីភ្នំពេញ
-រាជកិច្ច
-ដូចមាត្រា ៧ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨២១ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងបរិស្ថាន ចំនួន០៨រូប ដែលមានស្នាដៃល្អខិតខំបំពេញភារកិច្ច ស្តីពីកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន:

១-លោក	អេង	គីរុង	ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង
២-លោក	ទោ	ហួរ	ប្រធានមន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ

ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ:

១-លោក	អ៊ុម	ផាត់	ប្រធានមន្ទីរបរិស្ថានខេត្តកណ្តាល
២-លោក	ជូ	សុភក្ត្រ	ប្រធានមន្ទីរបរិស្ថានខេត្តរតនៈគីរី
៣-លោក	ពៅ	ម៉ិនថន	ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង
៤-លោក	ខាំ	ភន	ប្រធានមន្ទីរបរិស្ថានខេត្តស្វាយរៀង
៥-លោក	លន់	កាណែល	ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប
៦-លោក	មាស	សុផល	អគ្គនាយករងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤២២ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរសុខាភិបាលខេត្តក្រចេះ ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យសុខាភិបាល កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ:

១-លោក ជូ ស៊ុនហៃ ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក
២-លោក សេង ស៊ូ ប្រធានការិយាល័យគណនេយ្យ

ខ-មេដាយប្រាក់ការងារ:

១-លោកស្រី សឿ គឹមលាង បុគ្គលិកមន្ទីរសុខាភិបាលខេត្តក្រចេះ
២-លោកស្រី សឿ សារ៉ូ បុគ្គលិកមណ្ឌលសុខភាពថ្មគ្រែ
៣-លោកស្រី យឹម យ៉ារ៉ាត បុគ្គលិកមណ្ឌលសុខភាពព្រែកប្រសព្វ
៤-លោក គុត ញ៉ាន បុគ្គលិកមន្ទីរពេទ្យបង្អែកឆ្លូង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ត្រា: គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩២៣ ‧ អនក្រ ‧ បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៨រូប ដែលមានស្នាដៃចូលរួមចំណែកជាមួយអង្គការស្បៀងអាហារពិភពលោក **World Food Program** (WFP) ក្នុងការអនុវត្តការងារស្បៀងពលកម្ម និងចែកជូនប្រជាពលរដ្ឋក្រីក្រ នៅតាមឃុំគោលដៅតំបន់ដាច់ស្រយាល ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ:

១-លោក	ម៉េង	ចាន់ធឿន	មន្ត្រីគ្រប់គ្រងកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ
២-លោក	ខឡុ	សុផាណារិន	មន្ត្រីគ្រប់គ្រងកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ
៣-លោក	ខៀវ	ច័ន្ទធាទី	ប្រធានការិយាល័យរងតំបន់កំពង់ចាម
៤-លោក	ជួប	មុនី	ប្រធានការិយាល័យរងតំបន់កំពង់ស្ពឺ
៥-លោក	អ៊ុំ	និស្សិត	ប្រធានការិយាល័យរងតំបន់សៀមរាប

ខ-មេដាយប្រាក់ការងារ:

១-លោក	ហ្វូ	វដ្ឋា	មន្ត្រីត្រួតពិនិត្យបច្ចេកទេស
២-លោក	នុត	ថាវៈ	មន្ត្រីត្រួតពិនិត្យបច្ចេកទេស
៣-លោកស្រី	ម៉ៅ	សុមនា	មន្ត្រីត្រួតពិនិត្យបច្ចេកទេស

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ សីហា ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល:__
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣០៩

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកមន្ទីរពេទ្យកាល់ម៉ែត

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនគ្រូពេទ្យនិងមន្ត្រីរាជការ នៃមន្ទីរពេទ្យកាល់ម៉ែត ចំនួន៦៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច សង្គ្រោះព្យាបាលជម្ងឺធ្ងន់ជាសកលនានា ជូនប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១. លោកវេជ្ជបណ្ឌិត	យឹត សុនណារ៉ុម	ប្រធានការិយាល័យបច្ចេកទេស
២. លោកវេជ្ជបណ្ឌិត	ឌី ម៉ែតសុប្បន្នី	ប្រធានផ្នែក វះកាត់ "ខ"
៣. លោកស្រីឱសថការី	ឈឹម ម៉ូរី	ប្រធានផ្នែកឱសថស្ថាន
៤. លោកវេជ្ជបណ្ឌិត	ខិម សុខា	ប្រធានផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល
៥. លោកវេជ្ជបណ្ឌិត	អ៊ុន មាគា	ប្រធានផ្នែកពិគ្រោះជម្ងឺក្រៅ
៦. កញ្ញា	អ៊ឹម ឆេងស៊ី	អគ្គគិលានុបដ្ឋាយិការ
៧. លោកស្រីវេជ្ជបណ្ឌិត	ខិក លីនី	គ្រូពេទ្យព្យាបាល
៨. លោកវេជ្ជបណ្ឌិត	ឯម ស៊ីថារ៉ា	ប្រធាន Unité អេកូសាស្ត្រ
៩. លោកវេជ្ជបណ្ឌិត	អ៊ុក ម៉ារ៉ា	ប្រធាន Unité ជម្ងឺធ្ងន់

១០. លោកវេជ្ជបណ្ឌិត	ហាក់ ចាន់ធឿន	ប្រធាន Unité ស៊ីដា
១១. លោកឱសថបណ្ឌិត	ឌួត សុខុម	ប្រធាន Unité គីមីសាស្ត្រ
១២. លោកស្រីបណ្ឌិត	អ៊ឹង ដានី	ប្រធាន Unité បាក់តេរីសាស្ត្រ
១៣. លោកឱសថការី	គួច សាហឿង	ប្រធាន Unité លោហិតសាស្ត្រ
១៤. លោក	ជិន ទិសាល	ប្រធានការិយាល័យគណនេយ្យ
១៥.លោកវេជ្ជបណ្ឌិត	ស៊ុង អាន	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
១៦. លោកវេជ្ជបណ្ឌិត	ហេង្ស ចន្ទរះ	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
១៧. លោកវេជ្ជបណ្ឌិត	ឈាង ហេង	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
១៨. លោកវេជ្ជបណ្ឌិត	ឌិន វណ្ណៈ	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
១៩. លោកវេជ្ជបណ្ឌិត	កែត ប៊ុនឆោម	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
២០. លោកវេជ្ជបណ្ឌិត	ថន សុភាន	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
២១. លោកវេជ្ជបណ្ឌិត	ឡូច ចាន់ថន	គ្រូពេទ្យឯកទេសរូបភាពវេជ្ជសាស្ត្រ
២២. លោកវេជ្ជបណ្ឌិត	ឃឹម វឌ្ឍនៈ	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៣. លោកស្រីវេជ្ជបណ្ឌិត	ស្រី វិបុល្ល	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៤. លោកវេជ្ជបណ្ឌិត	ឆា សុខឡេង	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៥. លោកវេជ្ជបណ្ឌិត	ឈុន សុជាតិ	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៦. លោកវេជ្ជបណ្ឌិត	ឃឹម សុខលីន	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៧. លោកវេជ្ជបណ្ឌិត	អ៊ុក ផល្លា	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៨. លោកវេជ្ជបណ្ឌិត	ម៉េង អួង	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
២៩. លោកវេជ្ជបណ្ឌិត	ណុំ ធីរៈ	គ្រូពេទ្យព្យាបាលផ្នែកសង្គ្រោះបន្ទាន់
៣០. លោកវេជ្ជបណ្ឌិត	ហ៊ី សុភម៉ានិត	គ្រូពេទ្យព្យាបាលជម្ងឺទូទៅ “ក៤”
៣១. លោកវេជ្ជបណ្ឌិត	ប៊ុន ឆាប៊ូលី	គ្រូពេទ្យព្យាបាលជម្ងឺទូទៅ “ក៤”
៣២. លោកវេជ្ជបណ្ឌិត	ស៊ី សុត្ថា	គ្រូពេទ្យព្យាបាលជម្ងឺទូទៅ “ក៤”
៣៣. លោកវេជ្ជបណ្ឌិត	ជា ផែន	គ្រូពេទ្យព្យាបាលជម្ងឺទូទៅ “ក៤”

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១. លោកវេជ្ជបណ្ឌិត	ជឹង ប្រាមោទ្យ	ប្រធាន Unité វះកាត់ប្រដាប់រំលាយអាហារ
២. លោកវេជ្ជបណ្ឌិត	ឌ៉ាល់ ប៊ុណ្ណា	ប្រធាន Unité ឈឺចាប់
៣. លោកវេជ្ជបណ្ឌិត	អ៊ុង ចន្ទ្រាវុធ	ប្រធាន Unité ច្រមុះ ក្រពះ ពោះវៀន
៤. លោកវេជ្ជបណ្ឌិត	ចិន្ត សំឡេង	ប្រធាន Unité ប្រសាទសាស្ត្រ
៥. លោកវេជ្ជបណ្ឌិត	ឈឹម វឌ្ឍនា	ប្រធាន Unité លាងឈាម
៦. លោកស្រីវេជ្ជបណ្ឌិត	អ៊ឹម សិទ្ធិភារម្យ	ប្រធាន Unité ប្រពោធនកម្មទារក
៧. លោកវេជ្ជបណ្ឌិត	សុខ ប៊ុនថា	ជំនួយការប្រធាន Unité វះកាត់បែកបាក់ឆ្អឹង
៨. លោកស្រីវេជ្ជបណ្ឌិត	ឯក ម៉េងលី	ជំនួយការប្រធានផ្នែកសម្ភព
៩. លោក	ម៉ៅ សុខា	នាយសាលផ្នែកសង្គ្រោះបន្ទាន់
១០. លោក	មុត សំផន	នាយសាលផ្នែករូបភាពវេជ្ជសាស្ត្រ

១១. លោក	អ៊ុំ ទំណរថា	នាយសាលផ្នែកមន្ទីរពិសោធន៍
១២. កញ្ញា	តាន់ សោភ័ណ្ឌភារី	នាយសាលផ្នែកជម្ងឺទូទៅ "ក៤"
១៣. លោកស្រី	ម៉ៅ ម៉ាលីវណ្ណា	នាយសាលផ្នែកជម្ងឺទូទៅ "ក"
១៤. លោកស្រី	នាង ដល្លា	នាយសាលផ្នែកពិគ្រោះជម្ងឺក្រៅ
១៥. លោក	តាំង ឧត្តី	នាយសាលផ្នែកសល្យាគារ
១៦. លោក	ម៉ៅ ស្រ៊ុន	អគ្គានុរក្ស
១៧. លោក	ចេង ឧត្តា	ជំនួយការអគ្គានុរក្ស
១៨. លោក	ម៉ា កន្ទុល	មេក្រុមជាងទឹក ភ្លើង

គ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១. លោកស្រីវេជ្ជបណ្ឌិត	ហេង ច្រូណី	ជំនួយការប្រធានផ្នែកវះកាត់ប្រព័ន្ធប្រសាទ
២. លោកស្រី	សយ សុផល	នាយសាលផ្នែក វះកាត់ "ក"
៣. លោកស្រី	ម៉ៅ ស៊ិនណារី	នាយសាល Unité វះកាត់បែកចាក់កឆ្អឹង
៤. លោកស្រី	តាន់ សោភ័ណ្ឌ	នាយសាលផ្នែកប្រពោធនកម្ម
៥. លោកស្រី	ប៊ុនសាន ថុងយាន	នាយសាលផ្នែកវះកាត់ប្រព័ន្ធប្រសាទ
៦. លោក	សៀង សុធា	នាយសាលរួមប្រពោធនកម្ម សង្គ្រោះបន្ទាន់
៧. លោក	ឡើក រ៉ុង	នាយសាលសណ្តំភ្ញាក់ពីសណ្តំ
៨. លោកស្រី	ទិត លីណា	នាយសាលរងផ្នែកសម្ភព
៩. លោកស្រី	គីម គើ	នាយសាលផ្នែករោគស្ត្រី
១០. លោក	អ៊ុច ថាវ៉ាឧុង	នាយសាលជម្ងឺប្រព័ន្ធប្រសាទ
១១. លោក	ខៀវ ទី	នាយសាលជម្ងឺទូទៅ "ខ"
១២. លោក	សៀង ស៊ុន	នាយសាលផ្នែកវះកាត់ "ខ"
១៣. លោកស្រី	ឃុន យ៉ា	នាយសាលប្រពោធនកម្មប្រព័ន្ធប្រសាទ
១៤. លោក	ចាំង. ចាន់សាវ៉ាឧុង	នាយសាលថ្នើម គ្រពះ ពោះវៀន
១៥. លោកស្រី	ថា ចំន្ទ	នាយសាលរងប្រពោធនកម្មទារក

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងនាយកមន្ទីរពេទ្យកាល់ម៉ែត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ... ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៨៧៥. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកមន្ទីរពេទ្យកាល់ម៉ែត

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនគ្រូពេទ្យនិងមន្ត្រីរាជការ នៃមន្ទីរពេទ្យកាល់ម៉ែត ចំនួន៧៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច សង្គ្រោះព្យាបាលជម្ងឺឆ្លងគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-	លោកស្រី	ហែល កល្យាណា	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២-	លោក	ភួន កាន់	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៣-	លោក	ឃិន វណ្ណារ៉ាត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៤-	លោក	អ៊ិន ចរិទ្ធ	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៥-	លោក	សោម សុខ	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៦-	លោក	ខ៊ិត ស្រ៊ាន	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៧-	លោកស្រី	ប្រាក់ ម៉ានី	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៨-	លោក	ជួម ជំនោរ	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៩-	លោកស្រី	ជា សុធារី	អ្នកបច្ចេកទេសមន្ទីរពិសោធន៍

១០. លោក	ពេជ ពិន្ទុណា	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១១. លោក	ហេង អ៊ាំ	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១២. លោក	ម៉ៅ ស៊ីណាត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៣. លោក	ឆេព ស៊ីថុន	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៤. លោកស្រី	ឡូត សានី	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៥. លោកស្រី	សុខ ឆា	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៦. លោក	សោម សុខន	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៧. លោក	អ៊ិត ចិម	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៨. លោក	ចក ជីវន្ត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
១៩. លោក	សិត ណុប	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២០. លោកស្រី	នៅ ពុទ្ធារិន	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២១. លោកស្រី	សួស សុផាត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២២. លោក	ហួរ វណ្ណារិទ្ធ	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២៣. លោក	ហួរ គីមលី	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២៤. លោក	ចេក ប៊ុរ៉ាត់	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២៥. លោកស្រី	សុខ សាយ័ន្ត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
២៦. លោកស្រី	អ៊ុំ ចុច	គិលានុបដ្ឋាយិការមធ្យម
២៧. លោកស្រី	ឡាំ សាម៉េត	គិលានុបដ្ឋាយិការបឋម
២៨. លោកស្រី	អ៊ុច សិទ្ធី	អ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម
២៩. លោក	សុខ សុធី	គិលានុបដ្ឋាកមធ្យម
៣០. លោក	អោគ គីន	គិលានុបដ្ឋាកមធ្យម
៣១. លោក	សុខ ទី	គិលានុបដ្ឋាកមធ្យម
៣២. លោក	ភាំង ម៉េងហ៊ង	គិលានុបដ្ឋាកមធ្យម
៣៣. លោក	ស៊ឿន ដា	គិលានុបដ្ឋាកមធ្យម
៣៤. លោក	គីម សុភេន	គិលានុបដ្ឋាកមធ្យម
៣៥. លោក	រឹម សុធៈនៈ	គិលានុបដ្ឋាកមធ្យម
៣៦. លោកស្រី	ឌុច ផល្លា	គិលានុបដ្ឋាយិការមធ្យម
៣៧. លោក	ស៊ិន ចាន់តារា	គិលានុបដ្ឋាកមធ្យម
៣៨. លោក	ខួន ផល្លុង	គិលានុបដ្ឋាកមធ្យម
៣៩. លោក	ថោង បូរិន	គិលានុបដ្ឋាកបឋម
៤០. លោក	ឈឿង ហឿន	គិលានុបដ្ឋាកមធ្យម

៤១. លោកស្រី	យឹម ធាវី	គិលានុបដ្ឋាយិការមធ្យម
៤២. លោកស្រី	ថ៊ុន រិណារ៉ាត់	គិលានុបដ្ឋាយិការមធ្យម
៤៣. កញ្ញា	ម៉ុក ភួងកែវ	គិលានុបដ្ឋាយិការមធ្យម
៤៤. កញ្ញា	ម៉ុល ភា	គិលានុបដ្ឋាយិការមធ្យម
៤៥. លោក	ទ៊ាន សយ	គិលានុបដ្ឋាកមធ្យម
៤៦. លោក	ភាន់ ស្រ៊ា	គិលានុបដ្ឋាកមធ្យម
៤៧. លោកស្រី	ភេង សិរីវត្ថ	គិលានុបដ្ឋាយិការមធ្យម
៤៨. លោកស្រី	ញៀម សោភ័ណ្ឌ	គិលានុបដ្ឋាយិការមធ្យម
៤៩. លោកស្រី	លឿង សោភ័ណ្ឌ	គិលានុបដ្ឋាយិការមធ្យម
៥០. លោក	យ៉ាន ធា	គិលានុបដ្ឋាកមធ្យម
៥១. លោកស្រី	សំ សុខខឿន	គិលានុបដ្ឋាយិការមធ្យម
៥២. កញ្ញា	ថៃ ស៊ីណា	គិលានុបដ្ឋាយិការមធ្យម
៥៣. លោក	គីង សុជាតិ	គិលានុបដ្ឋាកមធ្យម
៥៤. លោក	គង់ សារួន	គិលានុបដ្ឋាកមធ្យម
៥៥. លោក	អ៊ឹម ស៊ីណា	គិលានុបដ្ឋាកមធ្យម
៥៦. លោកស្រី	ហែម រ៉ាណូដា	គិលានុបដ្ឋាយិការមធ្យម
៥៧. លោកស្រី	រ៉ុង ឆេងឡា	គិលានុបដ្ឋាយិការមធ្យម
៥៨. លោកស្រី	អ៊ិន សុចិន្តា	គិលានុបដ្ឋាយិកាមេធ្យម
៥៩. កញ្ញា	ហេង ថាវី	គិលានុបដ្ឋាយិការមធ្យម
៦០. លោក	ឯម ស៊ីគុណ្ណេត	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៦១. លោកស្រី	លាង សៀងហេង	អ្នកបច្ចេកទេសមន្ទីរពិសោធន៍
៦២. លោក	អ៊ាត ឧួនអេង	គិលានុបដ្ឋាកមធ្យម
៦៣. លោកស្រី	សេក ចន្ទី	គិលានុបដ្ឋាយិការមធ្យម
៦៤. លោកស្រី	ម៉ុន ភក្តិមុនី	គិលានុបដ្ឋាយិការមធ្យម
៦៥. កញ្ញា	អ៊ុក សុជាតិ	គិលានុបដ្ឋាយិការមធ្យម
៦៦. លោកស្រី	ហួន លីនដា	គិលានុបដ្ឋាយិការមធ្យម
៦៧. លោកស្រី	ផាលី នវី	គិលានុបដ្ឋាយិការមធ្យម
៦៨. លោកស្រី	សយ ចាន់ណាវី	គិលានុបដ្ឋាយិការមធ្យម
៦៩. លោក	គ្រីស បញ្ញាវ័ន្ត	គិលានុបដ្ឋាកមធ្យម

ខ.មេជាយច្រាក់ការងារ :

១. លោកស្រី	ខួន យី	កម្មការិនី
២. លោកស្រី	ថៃត ឡី	កម្មការិនី

៣. លោកស្រី	សួស ហួច	កម្មការិនី
៤. កញ្ញា	សឿន សុភាព	កម្មការិនី
៥. លោកស្រី	អ៊ិច សុម៉ាលី	កម្មការិនី
៦. លោកស្រី	កោះ វណ្ណី	កម្មការិនី
៧. លោក	ឈឹម យាន	កម្មករ
៨. លោក	នួន ចាន់សុធា	កម្មករ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងសុខាភិបាល និងនាយកមន្ទីរពេទ្យកាល់ម៉ែត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ /៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨២៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ -

ត្រូវបានបំពាក់មេដាយ ***សហមេត្រី ថ្នាក់មិត្តមិត្ត*** ជូនដល់នាយនគរបាលវៀតណាមចំនួន ០២ នាក់ បានចូលរួមកិច្ចសហប្រតិបត្តិការក្នុងការបង្ក្រាបបទល្មើសឆ្លងដែន ដូចជាករណីចាប់ជំរិតមនុស្ស ការជួញដូរគ្រឿងញៀន និងការទប់ស្កាត់អំពើភេរវកម្មបានល្អប្រសើរជាមួយនាយកដ្ឋានសន្តិសុខផ្ទៃក្នុង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១ លោកឧត្តមសេនីយ៍ត្រី NGUYEN VAN THANG តំណាងអគ្គនាយកដ្ឋានចារកម្ម នៃក្រសួងនគរបាលវៀតណាម
២ លោកវរសេនីយ៍ត្រី VUONG QUANG BAC មន្ត្រីស្ថានទូត

មាត្រា ២ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ~

ត្រូវបានបំពាក់មេដាយ **សហមេត្រី** តាមលំដាប់ថ្នាក់ ជូនដល់អង្គភាព និងនាយនគរបាលវៀតណាមចំនួន ០៤ នាក់ មានកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយក្រសួងមហាផ្ទៃកម្ពុជា លើវិស័យការងារបណ្តុះបណ្តាល ជំនាញ និងបានជួយឧបត្ថម្ភឧបករណ៍សំភារៈ ក្នុងនោះដើម្បីចូលរួមពិធីខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលប្រជាជនវៀតណាម ដូចមានរាយនាមខាងក្រោម ៖

ក- មេដាយសហមេត្រី ថ្នាក់មហាសេនា ៖

- ឯកឧត្តម ឧត្តមសេនីយ៍ទោ ĐANG VAN HIEU អនុរដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម

ខ- មេដាយសហមេត្រី ថ្នាក់សេនា ៖

១ លោកឧត្តមសេនីយ៍ត្រី TRAN GIA COUNG ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងនគរបាលវៀតណាម

២ លោកវរសេនីយ៍ឯកបំរុង TRAN VAN TAT ប្រធានការិយាល័យ[illegible]សហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

គ-មេដាយសហមេត្រី ថ្នាក់សេនា ៖

- អង្គភាពក្រសួងនគរបាលវៀតណាម

ឃ- មេដាយសហមេត្រី ថ្នាក់អស្សឫទ្ធិ ៖

- លោកវរសេនីយ៍ឯក HOANG TIEN HIEU លេខាអនុរដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤២៧ . ១០ អនក្រ.ឧក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ប្រគេន និងជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត និងធនធានចូលរួមជួយកសាង សមិទ្ធផលនានា នៅវត្ត អម្ពីវ័ន ស្ថិតក្នុង ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

១-	ព្រះតេជគុណ	សុគ្រ សុខុន	ព្រះចៅអធិការវត្តអម្ពីវ័ន
២-	លោក	ឈឹម សារឿន	សប្បុរសជន
៣-	លោក	ឈឹម តុលា	សប្បុរសជន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨២៩.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធាន និងកម្លាំងកាយ-ចិត្ត ចូលរួមជួយកសាង សមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្ត អម្ពវ័ន ស្ថិតក្នុងឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

១-	លោក	ឈឹម ចណ្ណៈ	សប្បុរសជន
២-	លោក	សេង សយ	សប្បុរសជន
៣-	ឧបាសក	អ៊ុំ ត្រឹង	គណៈកម្មការវត្តអម្ពវ័ន
៤-	ឧបាសក	ឈួន ឆាំ	គណៈកម្មការវត្តអម្ពវ័ន
៥-	ឧបាសក	អ៊ូច ខ្វី	គណៈកម្មការវត្តអម្ពវ័ន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣០.អនក្រ-បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ៣៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង សមិទ្ធផលនានាលើវិស័យព្រះពុទ្ធសាសនា និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តអង្គទុល ស្ថិតក្នុងឃុំមានជ័យ ស្រុកឈូក ខេត្តកំពត ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-	ព្រះតេជគុណ	ស៊ាង ពិសិដ្ឋ	ព្រះចៅអធិការវត្តអង្គទុល	បច្ច័យ ១០.៣២០ ដុល្លារ
២-	ឧបាសក	ម៉ែន ខន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ២១.០០០ ដុល្លារ
៣-	អ្នកស្រី	ម៉ែន សាវី	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ១០.២៥០ ដុល្លារ
៤-	ឧបាសក	ម៉ោង នាង	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ១០.២២០ ដុល្លារ
៥-	លោក	សាយ ថ្មុន	សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី	ថវិកា ១០.២១០ ដុល្លារ
៦-	កញ្ញា	នន់ ដារិទ្ធ	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ១០.១៥០ ដុល្លារ
៧-	លោក	ញឹក សាម៉េត	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.០០០ ដុល្លារ
៨-	លោក	នួន ឆា	សប្បុរសជននៅខេត្តឧត្តរមានជ័យ	ថវិកា ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-	ព្រះតេជគុណ	ឆា ទិត	អតីតព្រះចៅអធិការវត្តអង្គទុល	បច្ច័យ ៥.០០០ ដុល្លារ
២-	លោក	ជា ឆុន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ៦.៧៩០០ ដុល្លារ
៣-	លោក	ស្វាយ ផេន	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ៦.០២០ ដុល្លារ
៤-	លោក	ស្វាយ ផៃ	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ៦.០២០ ដុល្លារ
៥-	អ្នកស្រី	ម៉ៅ ប្រុញ	សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី	ថវិកា ៥.៨១០ ដុល្លារ
៦-	លោក	ចាន់ គីមសាន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.១៥០ ដុល្លារ
៧-	លោក	ឌុន ចាន់ដារ៉ា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.០៥០ ដុល្លារ
៨-	លោក	អ៊ុក សុខា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.០០០ ដុល្លារ
៩-	លោក	សាយ ផាត់	សប្បុរសជននៅខេត្តកំពត	ថវិកា ៥.០០០ ដុល្លារ
១០-	អ្នកស្រី	នន់ ដារ៉ា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.០០០ ដុល្លារ
១១-	ឧបាសិកា	សំ សុផាណាថ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ	ថវិកា ៥.០០០ ដុល្លារ
១២-	លោក	កែវ វណ្ណាច់	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.០០០ ដុល្លារ
១៣-	លោក	នថ សត្យា	សប្បុរសជននៅខេត្តកំពត	ថវិកា ៥.០០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ:

១-	លោក	លន់ ម៉ិន	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ២.០២០ ដុល្លារ
២-	ឧបាសិកា	ត្រាំ ម៉ុន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១.៧២០ ដុល្លារ
៣-	លោក	ម៉ៅ ទិត	សប្បុរសជននៅខេត្តតាកែវ	ថវិកា ១.៥០០ ដុល្លារ
៤-	លោក	សូ យឿង	សប្បុរសជននៅខេត្តតាកែវ	ថវិកា ១.២៥០ ដុល្លារ
៥-	ឧបាសិកា	ខាត់ សារ៉ុម	សប្បុរសជននៅខេត្តតាកែវ	ថវិកា ១.១០០ ដុល្លារ
៦-	លោក	ជា ណារាត	សប្បុរសជននៅខេត្តកំពត	ថវិកា ១.១០០ ដុល្លារ
៧-	ឧបាសក	ស្រី ជា	សប្បុរសជននៅខេត្តកំពត	ថវិកា ១.០៥០ ដុល្លារ
៨-	អ្នកស្រី	ណាំ ផាណារាត	សប្បុរសជននៅខេត្តកំពត	ថវិកា ១.០២០ ដុល្លារ
៩-	លោកវេជ្ជបណ្ឌិត	ញឹម ម៉ត់	សប្បុរសជននៅខេត្តកំពត	ថវិកា ១.០១០ ដុល្លារ
១០-	លោក	សុខ ចាន់	សប្បុរសជននៅខេត្តតាកែវ	ថវិកា ១.០០០ ដុល្លារ
១១-	លោក	ឈឹម ផន	សប្បុរសជននៅខេត្តកំពត	ថវិកា ១.០០០ ដុល្លារ
១២-	ឧបាសិកា	មិន ឧន	សប្បុរសជននៅខេត្តកំពត	ថវិកា ១.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៣១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសមាមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយសមាមេត្រី ថ្នាក់ អស្សឫទ្ធិ ជូននាយទាហាន នាយទាហានរង ចំនួន០២រូប ជនជាតិបារាំង ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្ម និងសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ទោ Storaci Philippe ប្រធានបេសកកម្មសហប្រតិបត្តិការសន្តិសុខបារាំង

២-ព្រិន្ទបាលទោ Maidi Christoph ផ្នែកភស្តុភារនៃបេសកកម្មសហប្រតិបត្តិការសន្តិសុខបារាំង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible]៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣៧ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ ជូនលោក Colonel Kenchanh Nanthalangsy អនុព័ន្ធយោធាឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្ម និងសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ កន្លងមក ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៣៣. អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សរិទ្ធិ ជូននាយទាហាន នាយទាហានរង និងគ្រូភាសាជនជាតិអូស្ត្រាលី ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម ៖

១-លោកអនុសេនីយ៍ឯក	Maxine	McGlasson	ទីប្រឹក្សាយោបល់ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមនិងភាសា
២-លោកព្រិន្ទបាលឯក	Steve	Bourke	ជំនួយការសេនានុព័ន្ធយោធាអូស្ត្រាលី
៣-លោក	Robert	S.Smith	គ្រូភាសាអង់គ្លេស

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៨៣៤ .អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូន Mr. MIYASHITA HIROSHI សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកាសរុបចំនួន ២៥.០០០ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សាចំនួន០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់ ធ្វើខ្លោងទ្វារ ដងទង់ជាតិ និងបន្ទប់ទឹក ជូនដល់សាលាបឋមសិក្សា ទួលរវៀង - មីយាស៊ីតា ហ៊ីរូស៊ី ស្ថិតនៅឃុំល្វា ស្រុកពួក ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៣៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី ថ្នាក់ដឹកនាំក្រុងកិនធឺ ខេត្តសុកចាំង ខេត្តហ៊ូវយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងថ្នាក់ដឹកនាំយោធភូមិភាគទី ៩ នៃកងទ័ពប្រជាជនវៀតណាមចំនួន ០៦ រូប ដែលបានចងសម្ព័ន្ធមេត្រីភាព ចូលរួមសហប្រតិបត្តិការយ៉ាងល្អ ជាមួយខេត្តកំពង់ឆ្នាំង នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

- **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១-លោក	ត្រឹន ថាញ់ម៉ាន	TRAN THANH MAN	ប្រធានគណៈកម្មាធិការប្រជាជនក្រុងកិនធឺ
២-លោក	ង្វៀន ផុងក្វាង	NGUYEN PHONG QUANG	លេខាគណៈកម្មាធិការគណបក្សខេត្តហ៊ូវយ៉ាង
៣-លោក	វ៉ូ មិញជៀន	VO MINH CHIEN	លេខាគណៈកម្មាធិការគណបក្សខេត្តសុកចាំង
៤-លោក	ផាម វ៉ាងធូ	PHAM VANG THU	អនុប្រធានស្នងការនយោបាយយោធភូមិភាគទី៩

- **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនចំពោះ :

១-លោកស្រី	ង្វៀន ធីកាមហុង	NGYUN THI CAM HONG	ប្រធានមន្ទីរទំនាក់ទំនងក្រៅប្រទេស ក្រុងកិនធឺ
២-លោក	ង៉ូ មិញចិន	NGO MINH CHEN	ប្រធានអង្គភាព K 90

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានសម្រេចផលចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៨៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការដាក់ចូលនិវត្តន៍ និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឱ្យលោក **ស៊ុន សុខលី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ អភិបាលស្រុកត្បូងឃ្មុំ នៃខេត្តកំពង់ចាម ចូលនិវត្តន៍មុនកាលកំណត់ ។

មាត្រា ២ : ត្រូវបានតែងតាំងលោកស្រី **សិត ណៃសយ** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៨ ជាអភិបាលស្រុកត្បូងឃ្មុំ នៃខេត្តកំពង់ចាម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការទទួលស្គាល់ប្រធានកិត្តិយស គណៈកម្មាធិការកណ្តាល អាណត្តិទី ៥ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់ សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១២ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការប្រើប្រាស់ និងការការពាររូបកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- យោងតាមលទ្ធផលបោះឆ្នោតជ្រើសរើសគណៈកម្មាធិការកណ្តាល អាណត្តិទី ៥ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០
- យោងកំណត់ហេតុប្រជុំលើកទី ១ របស់គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា អាណត្តិទី ៥ ស្តីពី ការជ្រើសរើសបេក្ខភាពប្រធានកាកបាទក្រហមកម្ពុជា អាណត្តិទី ៥ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០
- យោងតាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

សម្រេច

មាត្រា ១: ត្រូវបានបញ្ចប់ការទទួលស្គាល់ប្រធានកិត្តិយស សមាសភាពគណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា ដែលបានទទួលស្គាល់ មុនថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០ ។

មាត្រា ២: ទទួលស្គាល់ប្រធានកិត្តិយស សមាសភាពគណៈកម្មាធិការកណ្តាល អាណត្តិទី ៥ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា ដូចខាងក្រោម៖

១. ប្រធានកិត្តិយស:

១. សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយស

២ គណៈកម្មាធិការកណ្តាល:

១.	លោកជំទាវ	**ប៊ុន រ៉ានី ហ៊ុនសែន**	ប្រធាន
២.	លោកជំទាវ	**អាន្នី សុខ អាន**	អនុប្រធានទី ១
៣.	លោកជំទាវ	**ជីង សុភាព**	អនុប្រធានទី ២
៤.	លោកជំទាវ	**អ៊ុក ម៉ាលី**	អគ្គលេខាធិការ
៥.	សម្តេចចៅហ្វាវាំង	**គង់ សំអុល**	សមាជិក
៦.	ឯកឧត្តមសាស្ត្រាចារ្យ	**មី សាមីឌី**	សមាជិក
៧.	ឯកឧត្តម	**ញឹម វណ្ណដា**	សមាជិក
៨.	លោកជំទាវ	**ឃួន សុដារី**	សមាជិកា
៩.	ឯកឧត្តម	**អ៊ុក ដាមរី**	សមាជិក
១០.	លោកជំទាវ	**ញ៉ែម សុផានី ខូន ញ៉ិល**	សមាជិកា
១១.	ឯកឧត្តមឧកញ៉ា	**ភុក អាន**	សមាជិក
១២.	ឯកឧត្តមឧកញ៉ា	**លី យ៉ុងផាត់**	សមាជិក
១៣.	ឯកឧត្តមឧកញ៉ា	**ម៉ុង ឫទ្ធី**	សមាជិក
១៤.	ឯកឧត្តមឧកញ៉ា	**គិត ម៉េង**	សមាជិក
១៥.	ឯកឧត្តម	**ហេង តៃគ្រី**	សមាជិក
១៦.	ឯកឧត្តម	**ពិត ចំណាន**	សមាជិក
១៧.	ឯកឧត្តម	**ភៅ គីមហួន**	សមាជិក
១៨.	ឯកឧត្តម	**ឈុន ស៊ីរុន**	សមាជិក
១៩.	ឯកឧត្តម	**ប៉ា សុជាតិវង្ស**	សមាជិក
២០.	ឯកឧត្តម	**ភីម គុណាវឌ្ឍន៍**	សមាជិក
២១.	លោកជំទាវ	**ម៉ែន ភក្ដី ហុក ឡុងឌី**	សមាជិកា
២២.	លោកជំទាវឧកញ៉ា	**លីម ឈីវហួរ**	សមាជិកា
២៣.	លោកជំទាវ	**គូ ហុងសួន**	សមាជិកា
២៤.	ឯកឧត្តម	**ទ្រី មេង**	សមាជិក

៣. សមាជិកបំរុង:

១.	លោកជំទាវ	**សន ម៉ារ៉ាដា**
២.	ឯកឧត្តម	**ជុំ កុសល**
៣.	លោក	**កែ ក្រានីត**

៤. ទីប្រឹក្សា:

១.	លោកជំទាវ	**ភៅ ភឿន ទៀ បាញ់**
២.	លោកជំទាវ	**សុខ កែវ ច័ន្ទ សារុន**
៣.	លោកជំទាវ	**ជា ខេង ស៊ុយ សែម**

៥. អគ្គលេខាធិការដ្ឋានៈ

១.	លោកជំទាវ	**ពុំ ចន្ទីនី**	អគ្គលេខាធិការ
២	លោកជំទាវ	**ម៉ែន នារីសោភ័គ**	អគ្គលេខាធិការរង

មាត្រា ៣: គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា ដែលបានជ្រើសរើសតាមការបោះឆ្នោត របស់មហាសន្និបាតទូទាំងប្រទេស នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១០ ត្រូវបំពេញភារកិច្ចទៅតាមអំណាច ដែលមានចែងនៅក្នុងមាត្រា ១៥ នៃលក្ខន្តិកៈរបស់កាកបាទក្រហមកម្ពុជា។

មាត្រា ៤: អគ្គលេខាធិការ ដែលជ្រើសតាំងដោយគណៈកម្មាធិការកណ្តាល ត្រូវបំពេញភារកិច្ចទៅតាមមុខនាទី ដែលមានចែងនៅក្នុងមាត្រា ២១ នៃលក្ខន្តិកៈរបស់កាកបាទក្រហមកម្ពុជា។

មាត្រា ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកាកបាទក្រហមកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងបណ្តាសមាសភាព ដែលមានរាយព្រះនាម និងនាម ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣៧ អនក្រ.តត ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០០៩ ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរ **លោក ម៉ោ សុផាន់ណារ៉េ** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ទៅក្នុង ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុង មាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៤៣៩ .អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានប្រគល់ឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូនលោក **កែវ ស៊ីនា** អត្តលេខ ០០១៨៣៨ នាយទាហាន ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្តា សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨០-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ ជូនលោក Colonel Hidemaro OHTO អនុព័ន្ធយោធាជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្ម និងសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ កន្លងមក ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ៨ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤១ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១..

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៧រូប នៃអង្គការអេស៊ាហ្គោស្ពែលមិស្សិន Asia Gospel Mission (AGM) នៃសាធារណរដ្ឋកូរ៉េ ដែលបានជួយទ្រទ្រង់ សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈកុំព្យូទ័រ និងភាសាបរទេស ព្រមទាំងជួយឧបត្ថម្ភកុំព្យូទ័រ និង ម៉ាស៊ីនបញ្ចាំងស្លាយ ដល់នាយកដ្ឋានកិច្ចការយោធាស៊ីវិល ក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសហមេត្រី ថ្នាក់ សេនា:

- Mr. Park Young Hwan — នាយកអង្គការ អេជីអឹម

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ:

1- Mr. Park Choul Su — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម
2- Mr. You Byung Ki — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម
3- Mr. Lee Jae Deuk — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម
4- Mr. So Chi Young — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម
5- Mr. Park Hwa Sook — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម
6- Mr.Kim Tae Kweon — សមាជិកគណៈកម្មាធិការ នាយកអង្គការ អេជីអឹម

មាត្រា ២..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់មេដាយការងារ ថ្នាក់ មាស ជូននាយនគរបាលជាតិ និង សប្បុរសជន ដែលមានស្នាដៃល្អគុណបំណាច់ខ្ពស់ក្នុងការចូលរួមចំណែក ជួយស្ថារ អភិវឌ្ឍន៍ សង្គម ជាតិលើគ្រប់វិស័យក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក	កើត សុខន្ត	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២- លោក	ទន់ ទៀង	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៣- លោក	ស៊ិន វិរៈ	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៤- លោក	ផាត់ ផល្លា	សប្បុរសជន
៥- លោក	ស្រេង ហ៊ាង	សប្បុរសជន
៦- លោក	ថន ផានិត	សប្បុរសជន
៧- លោក	ចុង សេងផល្លុន	សប្បុរសជន
៨- លោក	ពៅ និក	សប្បុរសជន
៩- លោក	ញ៉ែម វ៉ាន់ឡឿន	សប្បុរសជន
១០- លោក	យ៉ង់ ចន្ថា	សប្បុរសជន
១១- លោកស្រី	ជុំ វិសាល	សប្បុរសជន
១២- លោក	ជុំ វិសុទ្ធ	សប្បុរសជន
១៣- លោក	អ៊ុន សួន្ទទិត្យា	សប្បុរសជន
១៤- លោក	ពៅ សុទ្ធា	សប្បុរសជន
១៥- លោក	ស៊ីង្ហ គីមហុក	សប្បុរសជន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់មេដាយសុវត្ថារា ថ្នាក់ ធិបឌិន ជូននាយនគរបាលជាតិ មន្ត្រីរាជការ ដែលមានស្នាដៃល្អគុណបំណាច់ខ្ពស់ ក្នុងការចូលរួមចំណែក ជួយស្តារ អភិវឌ្ឍន៍ សង្គមជាតិលើគ្រប់វិស័យ ក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក	ឃួន ឈើល	នាយការិ. នាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
២- លោក	ស៊ុម សំអាត	នាយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ជាំស្រងាំ
៣- លោក	សួស សុខជារ៉ា	នាយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ចាំយាម
៤- លោក	សោម សុគន្ធ	នាយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ដូង
៥- លោក	តុប សុវណ្ណ	នាយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ កំពង់ផែអន្តរជាតិភ្នំពេញ
៦- លោក	សួន សុជាតិ	នាយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ សៀមរាប
៧- លោក	គីម រតនា	នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ចាំយាម
៨- លោក	ស៊ឹង ដារិន	នាយរងការិយាល័យ នាយកដ្ឋានអន្តោប្រវេសន៍
៩- លោក	សុខ សំណាង	នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ភ្នំដិន
១០- លោក	កែវ ជា	នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ បន្ទាយចក្រី
១១- លោក	គីម ឈុនអ៊ី	ប្រធានក្រុមប្រឹក្សាខណ្ឌចំការមន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបងគណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ០៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ជូន នាយនគរបាលជាតិ មន្ត្រីរាជការ លោក លោកស្រី និងសប្បុរសជន ដែលមានស្នាដៃល្អ គុណបំណាច់ខ្ពស់ ក្នុងការចូលរួមចំណែក ជួយស្តារអភិវឌ្ឍន៍ សង្គមជាតិលើគ្រប់វិស័យក្នុងស្រុកបាណន់ ខេត្តបាត់ដំបងដូចមានរាយនាមខាងក្រោម :

ក- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន :

១- លោកវរសេនីយ៍ឯក	សុខ ធឿន	អត្តលេខ ០៧៧៣ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក
២- លោកអនុសេនីយ៍ឯក	យ៉ោង រដ្ឋា	ជំនួយការឯកឧត្តមប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ
៣- លោក	សុខ តុលា	នាយការិ.សន្តិសុខ. ស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង
៤- លោក	កែវ នី	នាយរងការិ. នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៥- លោក	ប៊ិន សំអុល	ជំនួយការប្រធាននាយកដ្ឋានសន្តិសុខ ក្រសួងមហាផ្ទៃ
៦- លោក	ជា ចិន្តា	នាយផ្នែកនាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៧- លោក	ហាយ មករា	នាយផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៨- លោក	អ៊ី សុបុណ្ណា	នាយផ្នែកនាយកដ្ឋានចារកម្ម ក្រសួងមហាផ្ទៃ
៩- លោក	ហៀង សុត្ថា	នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត
១០- លោក	ចាំង ម៉េងស្រេង	មន្ត្រីនាយកដ្ឋានចារកម្ម ក្រសួងមហាផ្ទៃ
១១- លោក	លី សុខគួង	មន្ត្រីនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ
១២- លោក	កង ស៊ុផាន	សប្បុរសជន
១៣- លោក	ណាស់ សម្បត្តិ	សប្បុរសជន
១៤- លោក	គាំង កេងផេង	សប្បុរសជន
១៥- លោក	ហ៊ីល រស់	សប្បុរសជន
១៦- លោក	ហ៊ីល គប	សប្បុរសជន
១៧- លោក	ចាន់ ពិសី	សប្បុរសជន
១៨- លោក	គា ឡៃ	សប្បុរសជន

ខ- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់សេនា :

១- លោក	ហួរ ចន្ថា	មេបញ្ជាការរងវរការពារព្រំដែនទឹក
២- លោក	ស៊ូ ចន្ថា	នាយការិ.នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៣- លោក	អ៊ុំ វៃឡា	នាយរងការិ.នាយកដ្ឋាននគរបាលអន្តរជាតិ ក្រសួងមហាផ្ទៃ
៤- លោក	ស៊ុន សុវុធ	អធិការរងនគរបាល ក្រុងប៉ោយប៉ែត
៥- លោក	លឹម អៀង	នាយផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៦- លោកស្រី	ហែម ឫទ្ធី	នាយផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៧- លោក	ឆាយ យ៉ាង	នាយផ្នែកនាយកដ្ឋាននគរបាលព្រំដែនទឹក
៨- លោក	ជិន សីហា	នាយផ្នែកនាយកដ្ឋាននគរបាលព្រំដែនទឹក
៩- លោក	សុខ ប៊ុនថុន	នាយរងការិយាល័យនាយកដ្ឋាននគរបាលព្រំដែនទឹក
១០- លោក	ម៉ក់ មន្នីស័ក្ក	មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹក
១១- លោក	ម៉ៅ លីណា	មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹក
១២- លោក	អេង ប៊ុនធឿន	នាយប៉ុស្តិ៍នាយកដ្ឋាននគរបាលការពារ
១៣- លោក	មៀច ច័ន្ទ	មន្ត្រីនាយកដ្ឋាននគរបាលនគរបាលព្រំដែនទឹក

១៤- លោក	សោភ័ណ សីលា	មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹក
១៥- លោក	កងសុំអាត	នាយផ្នែកនាយកដ្ឋាននគរបាលព្រំដែនទឹក
១៦- លោក	សៅ វីរៈ	មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹក
១៧- លោក	ឈូក សារ៉	នាយរងផ្នែកនាយកដ្ឋាននគរបាលព្រំដែនទឹក
១៨- លោក	សោម ធីមណារិទ្ធ	នាយរងផ្នែកនាយកដ្ឋាននគរបាលព្រំដែនទឹក
១៩- លោក	សេង សុខា	នាយរងប៉ុស្តិ៍ទឹកល្អក់ ខណ្ឌទួលគោក
២០- លោក	តាំង ផារ៉	មន្ត្រីអគ្គាធិការដ្ឋាន
២១- លោក	សម្បត្តិ កុសល	មន្ត្រីនាយកដ្ឋានអន្តោប្រវេសន៍
២២- លោក	ហ៊ិត ឡុង	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុងក្រសួងមហាផ្ទៃ
២៣- លោក	គង់ សៅរុន	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៤- លោក	លុយ ថាន	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៥- លោក	មាន វាសនា	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៦- លោក	គង់ ទីលីន	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៧- កញ្ញា	សំ ចេកម៉ាច	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៨- លោក	កែវ ឈន	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
២៩- លោក	លី ម៉េងឃាង	មន្ត្រី នាយកដ្ឋានចារកម្ម ក្រសួងមហាផ្ទៃ
៣០- លោក	ហៅ ទៀ	សប្បុរសជន
៣១- លោក	យ៉ុន ហ៊ួរ	សប្បុរសជន
៣២- លោក	ហេង គីមឡេង	សប្បុរសជន
៣៣- លោក	សេង គង់	សប្បុរសជន
៣៤- លោក	គីម ឡេងជារ៉	សប្បុរសជន
៣៥- លោក	នុត លី	សប្បុរសជន
៣៦- លោក	ក្រាម ស៊ុន្ទលី	សប្បុរសជន

គ- **មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់អស្សរិទ្ធិ** ៖

១- លោក	អ៊ុច ស៊ីផាល្លី	មេធាវី
២- លោក	កែវ សាម៉ីឌី	នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិភ្នំសំណរ
៣- លោក	ម៉ិច ស៊ីណារ៉ា	នាយរងការិ. នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៤- លោក	នៅ កេរ្តិ	នាយផ្នែក នាយកដ្ឋានសណ្ដាប់ធ្នាប់ ក្រសួងមហាផ្ទៃ
៥- លោក	អ៊ុំ ភាជ	នាយរងផ្នែក នាយកដ្ឋានសណ្ដាប់ធ្នាប់ ក្រសួងមហាផ្ទៃ
៦- លោក	ប៊ុក សាលីន	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៧- លោក	ប្រាជ្ញ ម៉ាលីស	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៨- លោក	ធៀម គន្ធា	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
៩- លោក	ព្រំ វុទ្ធា	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១០- លោក	ឡុង ប៊ុនរ៉េត	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១១- លោក	យ៉ិន ប៊ុនថេង	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១២- លោក	ម៉ម សារ៉េង	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១៣- លោក	ឌិន វណ្ណៈ	នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១៤- លោក	ទិត្យ វិច្ឆិកា	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១៥- លោក	អ៊ឹង រដ្ឋា	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១៦- លោក	ជុំយ តារាពិសី	មន្ត្រី នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្រសួងមហាផ្ទៃ
១៧- លោក	ម៉ម សុភ័ក្រ្ត	មន្ត្រី នាយកដ្ឋានចារកម្ម ក្រសួងមហាផ្ទៃ
១៨- លោក	ស៊ឹម វុទ្ធី	សប្បុរសជន
១៩- លោក	សាន ហ៊ិន	សប្បុរសជន
២០- លោក	សាមុន ដន	សប្បុរសជន
២១- លោក	ឡាង ឡេង	សប្បុរសជន
២២- លោក	ឡុង ចន្ថា	សប្បុរសជន
២៣- លោក	ស៊ាត ប៊ុនហួរ	សប្បុរសជន
២៤- លោក	គិត ហួរ	សប្បុរសជន
២៥- លោក	ចាន់ វិទូរ	សប្បុរសជន
២៦- លោក	ដូរស៊ីនក្ក អុស្តាប់	សប្បុរសជន
២៧- លោក	ស៊ រ៉ ខន្តី	សប្បុរសជន
២៨- លោក	ហាក់ សុខហាន	សប្បុរសជន
២៩- លោកស្រី	ស៊ុង្គ ច័ន្ទនី	សប្បុរសជន

មាត្រា២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤៥.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១ ៖ ត្រូវបានតែងតាំងលោក **ឃុន ស្រ៊ុន** ជាអគ្គនាយកមន្ទីរពិសោធន៍សំណង់ និងសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៤៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាសភាព

ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ដូចមានរាយនាមខាងក្រោម:

១- ឯកឧត្តម **សេង សក្ដា**	តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២- ឯកឧត្តម **ម៉ម អំណាត់**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣- លោក **នង ពិសិដ្ឋ**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤- លោកវេជ្ជ. **ឡូ ខាសនាគីរី**	តំណាងក្រសួងសុខាភិបាល	សមាជិក
៥- លោក **ឡាំន់ ស៊ូអៀង**	តំណាងនិយោជក	សមាជិក
៦- លោកឧកញ៉ាបណ្ឌិត **ណាង សុធី**	តំណាងនិយោជក	សមាជិក
៧- លោក **អាត់ ធន់**	តំណាងកម្មករនិយោជិតសមាជិក នៃ ប.ស.ស	សមាជិក
៨- លោក **ហេង ម៉ុនឈុន**	តំណាងកម្មករនិយោជិតសមាជិក នៃ ប.ស.ស	សមាជិក

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ៣ ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៨៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាសភាព អគ្គលេខាធិការរង

នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២០៩/១២១១ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- បានឃើញអនុក្រឹត្យលេខ ៨៤/អនក្រ/បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- យោងតាមសំណើរបស់ប្រធាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំង អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រដូចតទៅ :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខាវ គឹមហោ** អត្តលេខ ០២៤៣ ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ឯក **សួន សំណាង** អត្តលេខ ០០០២០៦ ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឧត្តមនាវីត្រី **គ្រួច គីមចុន** អគ្គលេខ ០០២៥២៨ ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឧត្តមសេនីយ៍ត្រី **តេខ សួន** អគ្គលេខ ០៧២៦២ ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៥៧ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែសីហាឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ១៧៣ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៩.០២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ២៩៥ ឧរថ.កឧ.លស ចុះថ្ងៃទី១២.០២.២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែនិង ថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេច ២ ហ្គាមេន ចុះថ្ងៃទី០៧.០៧.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន អេច ២ ហ្គាមេន តំណាងដោយ លោក SHEN QIHUI សញ្ជាតិចិន អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G10698183 ចុះថ្ងៃទី២១.០៩.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ No. 4064, Group 4 Quan Phong Xiao Qi Commune, District Feng-Huan, Zhejiang Province, P.R. CHINA ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖ *" អេច ២ ហ្គាមេន (H 2 GARMENT CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *" អាគារG ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសបញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ពេលវេលា អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ១៧៣ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៩.០២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អេច ២ ហ្គាមេន និង លិខិតលេខ ២៩៥ ឧរថ.កឧ.លស ចុះថ្ងៃទី១២.០២.២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

កន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៥៨ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ៣២៥ឧរថ.កឧ.ប្រក ចុះថ្ងៃទី២១.០៥.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមមីចិច (ខេមបូឌា) អិមអេហ្វជី ចុះថ្ងៃទី១៩.០៧.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ខេមមីចិច (ខេមបូឌា) អិមអេហ្វជី តំណាងដោយ លោកស្រី CHANG PAI, HUEI-CHU សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131437841 ចុះថ្ងៃទី.២៨០៣.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 3 FL, No.167,Wan Cheng St., Wen-Shan Dist Taipei, Taiwan, R.O.C. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141. Fax : 855-23-428263

-ឈ្មោះផលិតផល លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់ ៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖ *" ខេមមីថិច (ខេមបូឌា) អិមអេហ្វជី (CAMITEX (CAMBODIA) M FG CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *" ភូមិបឹងបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចផ្ទួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន . អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ៣២៥ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២១.០៥.២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ខេមមីថិច (ខេមបូឌា) អិមអេហ្វជី ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៤៥ ឧស.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែសីហាឆ្នាំ២០១០

<u>ប្រកាសបង្កើតរោងចក្រ</u>

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
